## សេចក្តីថ្លែងនៃគោលនយោបាយនៃការមិនរើសអើង(Nondiscrimination Statement of Policy)

ដោយអនុលោមតាមច្បាប់រដ្ឋ និងសហព័ន្ធស្តីពីសិទ្ធិមនុស្ស ទីភ្នាក់ងារគមនាគមន៍ នៅ Santa Clara Valley (VTA) ធានាថាគ្មានជនណាម្នាក់ ត្រូវបានគេរើសអើង ដោយផ្អែកលើពូជសាសន៍ ព័ណ៌សម្បុរ សាសនា សញ្ជាតិដើម អត្តសញ្ញាណនៃក្រុមជាតិពន្ធ អាយុ ពិការភាព ភេទ ការណែនាំផ្លូវភេទ ឬព័ត៌មានពន្ធុ ហាមឃាត់មិនឲ្យចូលរួមក្នុង បដិសេធអត្ថប្រយោជន៍ ឬសេវារបស់ ឬពុំនោះទេ ត្រូវបានជាកម្មវត្ថុនៃការរើសអើងនៅក្នុងរាល់កម្មវិធី សេវា ឬសកម្មភាពនានាដែលគ្រប់គ្រងដោយ VTA។

## សេចក្តីជូនដំណឹងក្រោមច្បាប់ស្តីពីអាមេរិកាំងមានពិការភាព (Notice under the Americans with Disabilities Act)
## ទីភ្នាក់ងារគមនាគមន៍ (Santa Clara Valley Transporation Agency)

ដោយអនុលោមតាមតម្រូវការនៃច្បាប់ស្តីពីអាមេរិកាំងមានពិការភាពនៃឆ្នាំ 1990 ("ADA") ទីភ្នាក់ងារគមនាគមន៍ នៅ Santa Clara Valley (VTA) នឹងមិនមានការរើសអើងប្រឆាំងនឹងបុគ្គលមានលក្ខណសម្បត្តិដែលមានពិការភាព ដោយសំអាងលើពិការភាពនៅក្នុងសេវា កម្មវិធី ឬសកម្មភាពនានា។

**ការងារ៖** ទីភ្នាក់ងារ VTA មិនមានរើសអើងដោយមានមូលដ្ឋានលើពិការភាពក្នុងការជួលបុគ្គលិកធ្វើការ ឬក្នុងការអនុវត្តន៍ការងារ ហើយប្រតិបត្តិតាម
រាល់បទបញ្ញត្តិនានាដែលផ្សព្វផ្សាយ ដោយគណកម្មាធិការឱកាសភាព សមភាពការងាររបស់សហរដ្ឋអាមេរិក (Equal Employment Opportunity)។

**ប្រសិទ្ធិភាពនៃទំនាក់ទំនង៖** ទីភ្នាក់ងារ VTA ជាទូទៅ តាមសម្នើសុំ នឹងផ្តល់ជំនួយ និងសេវាសមរម្យដែល នាំទៅរកការប្រស្រ័យទាក់ទងមានប្រសិទ្ធិភាពសម្រាប់ជនដែលលក្ខណសម្បត្តិមានពិការភាពដើម្បីឲ្យគេអាចចូលរួមដោយស្មើភាពនៅក្នុងកម្មវិធី សេវា និងសកម្មភាពនានា របស់ទីភ្នាក់ងារ VTA រួមទាំងអ្នកបកប្រែភាសាសញ្ញាមានគុណសម្បត្តិ សំណុំឯកសារជាប្រេល និងមធ្យោបាយផ្សេងទៀត ក្នុងការធ្វើព័ត៌មាន និងការប្រស្រ័យទាក់ទងនានាអាចទទួលបានដោយមនុស្សដែលមានការអន់ថយផ្នែក និយាយ ស្តាប់ ឬមើល។

**ការកែប្រែលើគោលនយោបាយ និងទម្រង់ការនានា៖** ទីភ្នាក់ងារ VTA នឹងធ្វើការកែប្រែសមហេតុផលទៅលើគោលនយោបាយ និងកម្មវិធីដើម្បីធានាថាមនុស្សមានពិការភាពមានឱកាសស្មើៗគ្នារីករាយសប្បាយជាមួយនឹងរាល់កម្មវិធី សេវា និងសកម្មភាពនានា។ ជាឧទាហរណ៍ បុគ្គលដែលមានសេវា
ផ្តល់ដោយសត្វគឺត្រូវបានស្វាគមន៍នៅក្នុងរថយន្ត មន្ទីរគ្រង់ស៊ីត និងការិយាល័យរដ្ឋបាលរបស់ទីភ្នាក់ងារ VTA ទោះបី ជាទូទៅសត្វត្រូវគេហាមឃាត់ក៏ដោយ។ ជនណាដែលតម្រូវឲ្យមានជំនួយជំនួស ឬសេវាសម្រាប់ការប្រស្រ័យទាក់ទងមានប្រសិទ្ធិភាព

ឬការកែប្រែនៃគោលនយោបាយ ឬទម្រង់ការ

ចូលរួមក្នុងកម្មវិធី សេវា ឬសកម្មភាពនៃទីភ្នាក់ងារ VTA គួរតែទាក់ទង៖

ADA Coordinator

Office of Diversity and Inclusion

3331 North First Street, B1

San Jose, CA 95134

(408) 321-2300

www.vta.org

សូមទាក់ទងមកអ្នកសម្រួលរបស់ ADA ឲ្យបានឆាប់ បើអាចធ្វើបាន តែមិនឲ្យយឺតជាង 72 ម៉ោង មុនកាលវិភាគព្រឹត្តិការណ៍។

ទីភ្នាក់ងារ ADA មិនតម្រូវឲ្យ VTA ធ្វើសកម្មភាពអ្វីដែលជាមូលដ្ឋានប្តូរនូវធម្ម ជាតិនៃកម្មវិធីរបស់វា ឬសេវា ឬ
ដាក់កំរិតផ្នែកហិរញ្ញវត្ថុហួសហេតុ ឬជា
ទម្ងន់ផ្នែក រដ្ឋបាល។

ប្តឹងថាមានកម្មវិធីមួយ សេវា ឬសកម្មភាពនៃទីភ្នាក់ងារ VTA មិនមានចេញចូលបានដោយជនដែលមានពិការភាពគួរ
តែបញ្ជូនដោយផ្ទាល់ទៅអ្នក
សម្រួល ADA របស់ VTA (ព័ត៌មានទាក់ទងខាងលើ)។

ទីភ្នាក់ងារ VTA នឹងមិនដាក់ថ្លៃលើសឲ្យទៅបុគ្គលណាមួយជាពិសេសដែលមានពិការភាព ឬក្រុមបុគ្គលមានពិការភាពឲ្យចេញថ្លៃ
សម្រាប់ផ្តល់ជំនួយជំនួស/សេវា ឬការកែប្រែមានហេតុផលនៃគោលនយោបាយ ដូចជាការទាញយកវត្ថុនានាពីទីតាំងដែលបើក
ជាសាធារណៈតែមិនអាចចេញចូលបាន
ដោយជនដែលប្រើរទេះរុញអ្នកពិការ។